**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤១ ស.សរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការទទួលបន្ទុករៀបចំបុណ្យសព ឯកឧត្តម ម៉ែន យ៉េត រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណូមពរ និង ការងារចាំបាច់

## សំរេច

**ប្រការ ១** : ត្រូវបានបង្កើតគណៈកម្មការចំរុះមួយ ដើម្បីរៀបចំបុណ្យសពឯកឧត្តម **ម៉ែន យ៉េត** រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ដែលមានសមាសភាព ដូចខាងក្រោម ៖

| | | |
|---|---|---|
| ១_អ្នកអង្គម្ចាស់ | ស៊ីសុវត្ថិ ប៉ាណារ៉ា ស៊ីរីវុឌ្ឍ | ប្រធាន |
| ២_ឯកឧត្តម | អ៊ុក សុជាតិ | អនុប្រធាន |
| ៣_ឯកឧត្តម | ជា គាន | អនុប្រធាន |
| ៤_ឯកឧត្តម | សេង លឹមនៅ | សមាជិក |
| ៥_ឯកឧត្តម | ប៊ុន សំ | សមាជិក |
| ៦_ឯកឧត្តម | យូ ស៊ីនឡុង | សមាជិក |
| ៧_ឯកឧត្តម | ជា សុខុម | សមាជិក |
| ៨_ឯកឧត្តម | ហ៊ុល ផានី | សមាជិក |
| ៩_ឯកឧត្តម | ឃឹម សារិទ្ធ | សមាជិក |
| ១០_ឯកឧត្តម | ម៉ប់ សារិន | សមាជិក |

| | | |
|---|---|---|
| ១១_ឯកឧត្តម | ទុយ គឿន | សមាជិក |
| ១២_ឯកឧត្តម | ជឹង ឈង | សមាជិក |
| ១៣_ឯកឧត្តម | ឥត សារ៉ាត់ | សមាជិក |
| ១៤_ឯកឧត្តម | តែ គុយស៊ាង | សមាជិក |
| ១៥_លោក | បួន លីមហេង | សមាជិក |
| ១៦_លោក | គង់ សារ៉ាន់ | សមាជិក |
| ១៧_លោក | គីម សុផាណា | សមាជិក |

**ប្រការ ២** : គណៈកម្មការនេះ មានភារកិច្ច :

_ទទួលបន្ទុករៀបចំបុណ្យសព ឯកឧត្តម **ម៉ែន យ៉េត** រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ អោយបានល្អប្រសើរ ស្របតាមប្រពៃណីជាតិ ។

_រៀបចំកម្មវិធីលំអិតសំរាប់បុណ្យសព ពិធីការ ទទួលភ្ញៀវជាតិ អន្តរជាតិ ដែលត្រូវអញ្ជើញ គោរពវិញ្ញាក្ខន្ធសព រៀបចំវិយោគកថា និងឯកសារផ្សេងៗដែលចាំបាច់ ។

_រៀបចំពិធីបូជាបូជាសពតាមប្រពៃណីសាសនា និងប្រពៃណីជាតិ ដោយសហការជិតស្និទ្ធជាមួយ គ្រួសារសព ។

_ដោះស្រាយថវិកាសំរាប់បំរើការងាររៀបចំពិធីបុណ្យសព ។

_រៀបចំក្បួនដង្ហែសព និងពិធីបូជាសពអោយល្អប្រសើរ ។

_គណៈកម្មការនេះអាចបង្កើតអនុគណៈកម្មការមួយចំនួនទៀត តាមតំរូវការចាំបាច់ ដើម្បីជាជំនួយការ ។

_គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រា របស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ។

_សមាជិកគណៈកម្មការត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ ។

**ប្រការ ៣** : ទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ប្រធានគណៈកម្មការអចិន្ត្រៃយ៍ រៀបចំបុណ្យជាតិ_អន្តរជាតិ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង ឯកឧត្តម អស់លោក ដូចមាន ចែងក្នុងប្រការ ១ ត្រូវអនុវត្តតាម សេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០០២*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៣*
- *ឯកសារ_កាលប្បវត្តិ*